# ប្រកាសព័ត៌មាន

## សេចក្តីថ្លែងការណ៍ ដោយអ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិ ស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា លោកសាស្ត្រាចារ្យ ស៊ូយ៉ា ប្រាសាទ ស៊ូបឺឌី

**រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១០**

"ប្រព័ន្ធតុលាការនៅកម្ពុជាកំពុងជួបប្រទះនឹងបញ្ហាប្រឈមជាច្រើន ក្នុងការផ្តល់យុត្តិធម៌ជូនប្រជាជននៃប្រទេសនេះ ជាពិសេសប្រជាជនក្រីក្រ និងប្រជាជនដែលគេមិនសូវគិតគូរដល់ " តាមប្រសាសន៍ របស់លោកសាស្ត្រាចារ្យ ស៊ូយ៉ា ស៊ូបឺឌី អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិ ស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ថ្លែងនៅថ្ងៃនេះ នៅរាជធានីភ្នំពេញ។ លោកសូមស្វាគមន៍ការអនុម័ត ច្បាប់ថ្មីជាបន្តបន្ទាប់នៅក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ រាប់ទាំង ក្រមព្រហ្មទណ្ឌថ្មី ច្បាប់ប្រឆាំងអំពើ ពុករលួយ និងក្រមនីតិវិធីព្រហ្មទណ្ឌ ដែលបានតាក់តែងឡើង ដើម្បីពង្រឹងប្រព័ន្ធយុត្តិធម៌។ "ទោះជា យ៉ាងណាក៏ដោយ គួបផ្សំនឹងកង្វះខាតធនធានគ្រប់គ្រាន់ កង្វះខាតស្ថាប័ន និងការរៀបចំស្ថាប័ន កង្វះខាតការយល់ដឹងពេញលេញអំពីបទដ្ឋានពាក់ព័ន្ធនឹងសិទ្ធិមនុស្ស និងការជ្រៀតជ្រែកពីមជ្ឈដ្ឋានខាងក្រៅ បញ្ហាហិរញ្ញវត្ថុ ឬបញ្ហាផ្សេងទៀត ក្នុងកិច្ចការតុលាការ បានធ្វើឲ្យស្ថាប័នមួយនេះ មិនអាចផ្តល់ការជឿទុកចិត្តដល់ប្រជាជននៅគ្រប់ស្រទាប់ជាន់ថ្នាក់បាន" អ្នករាយការណ៍ពិសេសបានមាន ប្រសាសន៍បន្ថែមយ៉ាងដូច្នេះ ។

តាមការបូកសរុបលទ្ធផលការងារក្នុងដំណើរបេសកកម្មស្វែងរកការពិតរយៈពេលដប់ថ្ងៃរបស់លោក អំពីការប្រព្រឹត្តទៅនៃប្រព័ន្ធតុលាការនៅកម្ពុជា នៅថ្ងៃព្រហស្បតិ៍នេះ លោកសាស្ត្រាចារ្យ បានធ្វើការសន្និដ្ឋានថា "អ្នកជាប់ឃុំឃាំងមានចំនួនច្រើនគួរឲ្យបារម្ភ ដោយសារមានចំណុចខ្វះខាតផ្សេងៗមួយចំនួន នៅក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ និងនៅករណីនៃការអនុវត្តន៍យុត្តិធម៌មិនទាន់បានត្រឹមត្រូវរបស់តុលាការ គឺនៅមានច្រើនខ្លាំងណាស់។ កត្តាកំរិតលើសមត្ថភាពរបស់តុលាការឲ្យអនុវត្តន៍ ស្របតាមអាណត្តិការងាររបស់ខ្លួន តាមឋានានុក្រមដែលបានកំណត់ក្នុងរដ្ឋធម្មនុញ្ញកម្ពុជា គឺមានច្រើនផ្ទត់ច្រើនថ្នាក់។ ម្យ៉ាងវិញទៀត មានកត្តាខ្លះទាក់ទងនឹងចន្លោះប្រហោងនៃសមត្ថភាពរបស់ខ្លួន ក្នុងការផ្តល់យុត្តិធម៌ (រាប់ទាំងបញ្ហាថវិកា ហេត្ថារចនាសម្ព័ន្ធ និងការបណ្តុះបណ្តាល) កត្តាកំរិតផ្សេងទៀតទាក់ទងនឹងភាពចន្លោះប្រហោងនៃចំណេះដឹងរបស់ពួកគាត់លើផ្នែកច្បាប់សិទ្ធិមនុស្ស ដែលនាំឲ្យគាត់

មានការពិបាកក្នុងការបកស្រាយច្បាប់ ឲ្យស្របតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ។ ថៅក្រមជាច្រើន អាចមានការសន្យាចាំបាច់ ដើម្បីផ្តល់យុត្តិធម៌ទៅតាមច្បាប់ ប៉ុន្តែសំរាប់ករណីជាច្រើន ដែលការសន្យា នេះ ត្រូវបានសម្របសម្រួល ដោយការជ្រៀតជ្រែកពីមជ្ឈដ្ឋានខាងក្រៅ ហើយសំរាប់អ្វីផ្សេងពីនេះ ការសន្យាគឺមិនមានទេ៉ ។

ទន្ទឹមនឹងការពិចារណាអំពីស្ថានភាពទូទៅនៃប្រព័ន្ធតុលាការនៅកម្ពុជា លោកសាស្ត្រាចារ្យ ស៊ូប៊ីឌី ក៏ពិនិត្យមើលផងដែរ អំពីការងាររបស់ប្រព័ន្ធតុលាការក្នុងវិស័យច្បាប់ជាក់លាក់ ។ លោកបាន លើកអំពីកង្វល់ជាក់លាក់មួយចំនួនទាក់ទងនឹងតួនាទីរបស់តុលាការ ក្នុងការការពារសេរីភាពខាងការ សំដែងមតិ និងក្នុងករណីដែលទាក់ទងនឹងសិទ្ធិដីធ្លី ។

៉ខ្ញុំមានកង្វល់អំពីផលប៉ះពាល់នៃទំនាស់ដីធ្លី សម្បទានដី និងការតាំងទីលំនៅថ្មី ដល់ជីវភាព រស់នៅរបស់ប្រជាជនសាមញ្ញ ទាំងនៅទីប្រជុំជន ទាំងនៅតំបន់ជនបទ ការអនុវត្តន៍យុត្តិធម៌មិនបាន ត្រឹមត្រូវ និងការរួមតូចនៃលំហរនយោបាយ និងការជជែកដេញដោលគ្នាអំពីបញ្ហាសំខាន់ៗក្នុងសង្គម ដោយសារការប្រើប្រាស់វិសមាមាត្រនៃបណ្តឹងបរិហារកេរ្តិ៍ ការផ្សាយព័ត៌មានមិនពិត និងការញុះញង់ ប្រឆាំងនឹងអ្នកសារព័ត៌មាន សកម្មជនសិទ្ធិមនុស្ស និងអ្នករិះគន់រដ្ឋាភិបាល៉ នេះបើតាមការសង្កេត របស់លោក ៉ ខ្ញុំសូមអំពាវនាវដល់រាជរដ្ឋាភិបាលកម្ពុជា ឲ្យដាក់ចេញនូវវិធានការជាបន្ទាន់ ដើម្បីពង្រឹង ឯករាជ្យភាព និងសមត្ថភាពនៃប្រព័ន្ធតុលាការ ដើម្បីឲ្យស្ថាប័ននេះអាចអនុវត្តការងាររបស់ខ្លួន ជា ស្ថាប័នមួយដែលមានសមត្ថភាពផ្តល់យុត្តិធម៌ដល់ជនគ្រប់រូបនៅកម្ពុជា។ បើសិនជា អ្នកជាជនក្រីក្រ ទន់ខ្សោយ ហើយត្រូវគេដកហូតដីធ្លីរបស់អ្នក អ្នកទំនងជាមានឱកាសតិចតួច នឹងទទួលបានការដោះ ស្រាយតាមផ្លូវច្បាប់ តាមរយៈប្រព័ន្ធគ្រប់គ្រងរដ្ឋបាលដីធ្លី ឬតាមរយៈតុលាការ៉

លោកសាស្ត្រាចារ្យ ស៊ូប៊ីឌី បានកត់សំគាល់ឃើញអំពីសមិទ្ធិផលគួរជាទីគាប់ចិត្ត ដែលកម្ពុជា សំរេចបាននៅក្នុងវិស័យជាច្រើន និងបានលើកទឹកចិត្តដល់រដ្ឋាភិបាលឲ្យជំរុញអនុវត្តតទៅទៀតនូវ កម្មវិធីសកម្មភាពរបស់ខ្លួន ដើម្បីលើកកំពស់ និងពង្រឹងប្រព័ន្ធតុលាការ និងធ្វើឲ្យប្រសើរឡើងថែមទៀត ដល់ស្ថានភាពសិទ្ធិមនុស្ស។ លោកបានថ្លែងសរសើរថា កម្ពុជាគឺជាប្រទេសមួយក្នុងចំណោមប្រទេស ចំនួនតិចតួចបំផុត ដែលបានទទួលយកអនុសាសន៍ទាំង៩១ របស់ក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហ ប្រជាជាតិនៅដើមឆ្នាំនេះ ដែលជាផ្នែកមួយនៃការពិនិត្យរបាយការណ៍ទៀតទាត់ជាសកល រៀងរាល់ បួនឆ្នាំម្តង។ លោកមានប្រសាសន៍បន្តទៀតថា ឥឡូវនេះ ដល់ពេលដែលរាជរដ្ឋាភិបាល ត្រូវបង្កើត តារាងពេលវេលាមួយជាក់ច្បាស់ហើយ ដើម្បីអនុវត្តអនុសាសន៍ទាំងនេះប្រកបដោយអត្ថន័យ ហើយ លោកបានស្នើផ្តល់ការជួយឧបត្ថម្ភរបស់លោក ដល់រាជរដ្ឋាភិបាលក្នុងបញ្ហានេះ។ លោកបានលើក

ទឹកចិត្តដល់រាជរដ្ឋាភិបាលឲ្យធ្វើការជាមួយអ្នកពាក់ព័ន្ធសំខាន់ៗឯទៀត រាប់ទាំងអង្គការសង្គមស៊ីវិលនានា ដើម្បីអនុវត្តអនុសាសន៍ ទាំងនេះ។

ក្នុងអំឡុងពេលបំពេញបេសកកម្មនេះ លោកសាស្ត្រាចារ្យ ស៊ូបឺឌី បានចូលបង្គំគាល់ព្រះមហាក្សត្រ ព្រះបាទបរមនាថនរោត្តម សីហមុនី ដែលព្រះអង្គទ្រង់គង់ជាព្រះប្រធាននៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ជាស្ថាប័នមួយដែលទទួលបានការជឿទុកចិត្តច្រើនជាងគេ ក្នុងចំណោមស្ថាប័នឯទៀតដែលមានភារកិច្ចស្នើតែងតាំងចៅក្រម និងដាក់វិន័យលើចៅក្រមដែលអសមត្ថភាព និងចៅក្រមពុករលួយ។ លោកក៏បានជួបជាមួយឯកឧត្តម ហោ ណាំហុង ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការបរទេស ឯកឧត្តម ឱម យ៉ិនទៀង ប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ឯកឧត្តម ឌិត មុន្ទីប្រធានតុលាការកំពូល និងចៅក្រម ព្រះរាជអាជ្ញា និងមន្ត្រីរដ្ឋាភិបាល ព្រមទាំងជាមួយតំណាងសង្គមស៊ីវិល និងជនរងគ្រោះដោយការរំលោភសិទ្ធិមនុស្ស។ លោកបានវាយតំលៃខ្ពស់ចំពោះឆន្ទៈរបស់ដៃគូពិភាក្សាទាំងអស់របស់លោក ទាំងនៅក្នុងរាជរដ្ឋាភិបាល ទាំងនៅក្នុងប្រព័ន្ធតុលាការ ការទទួលស្គាល់អំពីចំណុចខ្វះខាតផ្សេងៗ និងការចូលរួមពិភាក្សាប្រកបដោយន័យស្ថាបនា និងដែលមានអត្ថន័យ អំពីការផ្លាស់ប្តូរ និងការកែទម្រង់ ។

លោកសាស្ត្រាចារ្យ ស៊ូបឺឌី នឹងដាក់ស្នើរបាយការណ៍មួយ ដែលមានអនុសាសន៍ពិស្តាររបស់លោកនិយាយអំពីកំណែទម្រង់ប្រព័ន្ធតុលាការ និងវិធានការមួយចំនួនផ្សេងទៀតដែលនឹងត្រូវដាក់ចេញនៅកម្ពុជាដើម្បីដាក់ទៅក្រុមប្រឹក្សាសិទ្ធិមនុស្ស នាសម័យប្រជុំបន្ទាប់របស់ខ្លួននៅទីក្រុងហ្សឺណែវក្នុងខែកញ្ញា ឆ្នាំនេះ ។

************

*លោកសាស្ត្រាចារ្យស៊ូយ៉ា ស៊ូប៊ែឌី ជាសាស្ត្រាចារ្យផ្នែកនីតិអន្តរជាតិ នៅសាកលវិទ្យាល័យ លីដស៍ និងជាមេធាវីនៅប្រទេសអង់គ្លេស ហើយលោកក៏ជាមេធាវីនៅប្រទេសនេប៉ាល់ផងដែរ ។ អ្នករាយការណ៍ពិសេស គឺជាអ្នកជំនាញការឯករាជ្យដែលត្រូវបានតែងតាំងដោយក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ ដើម្បីតាមឃ្លាំមើល និងរាយការណ៍អំពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ។*

*រាល់**សំណើរព័ត៌មាន** ទាក់ទងនឹងអ្នករាយការណ៍ពិសេស អាចផ្ញើមកការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលសិទ្ធិមនុស្សនៅកម្ពុជា។ សូមទំនាក់ទំនងមកកញ្ញា Riona Judge McCormack (Tel: +855 012790178 / email: rjudgemccormack@ohchr.org) ឬ លោក ទូច ហួន (Tel: +855 012 476 493 / email: htouch@ohchr.org).*